លោកគ្រូ **ឡុច ផ្លែង**

(១៩៣៨-២០២០)

Loch Phléng

ដោយ
បណ្ឌិតសភាចារ្យ ឃីងហុកឌី

កើតនៅឆ្នាំ១៩៣៨, កុមារ **ផ្លែង**ជាញាតិវង្ស ស្ដេចត្រាញ់ក្រុងបាត់ដំបង នាម **អភៃវង្ស** (អភ័យវង្ស) ជាត្រកូលដើមដំបូងរបស់គ្រួសារ។ តែនាពេល ខេត្តបាត់ដំបងបានត្រឡប់មកជាដែន

ដីខ្មែរវិញនោះ គ្រួសារកុមារ **ផ្ទែង** បានត្រូវរដ្ឋអំណាចបារាំងនិងខ្មែរឲ្យដូរត្រកូល ពី **អភៃវង្ស** មកជា ត្រកូល **ឡុច** វិញ។[1]

បិតានាមលោកនាយ **ឡុច ឡាច់** ហើយមាតានាម អ្នកស្រី **លី** ហៅ **ប៉ែ** ឬ **អ៊ី** មានបុត្រាបុត្រី៨នាក់ សញ្ជាតិខ្មែរ រស់នៅទីរួមខេត្តបាត់ដំបង។[2]

បន្ទាប់ពីបានបញ្ចប់ការសិក្សានៅសាលាបឋម មក យុវជន **ឡុចផ្ទែង** បានមកចូលរៀននៅថ្នាក់ទី៦ក្នុងឆ្នាំ១៩៥០ នៅភ្នំពេញក្នុងគរុវិទ្យាល័យសម្រាប់ទៅប្រឡងចូលធ្វើការជាបុគ្គលិកក្រសួងអប់រំជាតិ (Ecole Normale) នាពេលអនាគត អាស្រ័យដោយមានអាយុច្រើនមិនអាចចូលរៀននៅមធ្យមសិក្សាផ្នែកទូទៅបាន (Enseignement secondaire du cycle général)។

បន្ទាប់ពីបានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ (Diplôme de l´Enseignement secondaire du 1er cycle) ក្នុងឆ្នាំ១៩៥៤ លោកបានប្រឡងចូលធ្វើជាគ្រូបង្រៀនបឋមសិក្សា (Instituteur de l´enseignement primaire et complémentaire) ។ បន្ទាប់ពីបាន

---

[1] សូមអាន LOCH Chhanchhai, « Chronique des vice-rois de Battambang (XVIIIe-XXIe siècles) : du régent Bên de Battambang à la famille Aphaiwong du Siam », *Péninsule* n° 68 – 2014, p.100. « La famille Huoṅ Kaṃbhot ou *lok nāy* Caṃroen résidant à Pāt ṭaṃpaṅ fut forcée par les autorités françaises de changer de patronyme Abhāyvaṅs fut transformé en Ḷuc. »

[22] សូមអានបន្ថែម អត្ថបទសិក្សាទាំងមូលរបស់ LOCH Chhanchhai, « Chronique des vice-rois de Battambang (XVIIIe-XXIe siècles) : du régent Bên de Battambang à la famille Aphaiwong du Siam », *Péninsule* n° 68 – 2014, pp. 9-103.

ចេញពីសាលាគរុកោសល្យលោកបានទៅបំពេញការងារជាគ្រូបង្រៀនបឋមសិក្សានៅខេត្តបាត់ដំបងក្នុងឆ្នាំសិក្សា១៩៥៥-៥៦។

បន្ទាប់ពីបានបំពេញការងារអស់រយៈពេល៣ឆ្នាំ លោកបានប្រឡងជាប់ចូលរៀននៅវិទ្យាស្ថានជាតិគរុកោសល្យជំនាន់ទី២នាឆ្នាំសិក្សា១៩៥៩- ១៩៦១។

ពេលរៀន២ឆ្នាំចប់នៅស្ថាប័ននេះនាឆ្នាំ១៩៦១ លោកបានទទួលការតែងតាំងជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ បង្រៀននៅវិទ្យាល័យនាខេត្តបាត់ដំបងក្នុងឆ្នាំសិក្សា១៩៦២-១៩៦៣ ។ បន្ទាប់មក លោកបានផ្លាស់មកបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិចាប់ពីឆ្នាំសិក្សា១៩៦៣នេះមក។

ក្រោយពីបានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរពីមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រមក លោកបានទទួលការតែងតាំងជាសាស្ត្រាចារ្យមធ្យមសិក្សា ទុតិយភូមិ និងបានទទួលតំណែងជាអធិការបច្ចេកទេសភាសានិងអក្សរសាស្ត្រខ្មែរនៅមធ្យមសិក្សានៃប្រទេសកម្ពុជាទាំងមូយ ហើយនិងបានធ្វើការជាប្រធាន **គណៈកម្មការអនុម័តពាក្យ** *ក្នុងគម្រោងកម្មវិធី***ខេមរយានកម្ម** *រហូតដល់ឆ្នា១៩៧៣ ហើយលោកក៏បានបង្រៀនមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ រៀងមករហូត ដល់១៩៧៣ ព្រោះនាពេលនោះលោកគ្រូឡុចឆ្វៃជ័បានទទួលអាហារូបករណ៍បារាំង « គ្រូស » (CROUS) មកសិក្សាស្រាវជ្រាវប្រឡងយកសញ្ញាប័ត្រថ្នាក់បណ្ឌិតតតិយភូមិនាក្រុងប៉ារីស*

នៅ វិទ្យាស្ថានសិក្សា ភាសាវិទ្យា និង ស័ទ្ទវិទ្យា នៅសាកល វិទ្យា ហេព្យារបោនទី៣ ក្រុងប៉ារីស (Institut d’Etudes Linguistiques et Phonétiques de l’Université de la Sorbonne Nouvelle de Paris 3) ។

សាស្ត្រាចារ្យ **ឡុចផ្ទៃជ៍** បានសិក្សាចប់នាឆ្នាំ១៩៧៤ហើយ បានធ្វើរបាយការណ៍ បញ្ចប់ឆ្នាំ១៩៧៣-៧៤ថ្នាក់បណ្ឌិតតតិយ ភូមិ នៅវិទ្យាស្ថានសិក្សាភាសាសាស្ត្រ និង ស័ទ្ទសាស្ត្រ នៃសាកល វិទ្យាល័យហេព្យារបោនទី៣ដោយមាន ប្រធានបទស្ដីពី **ប្រព័ន្ធមូលស័ទ្ទវិទ្យាខ្មែរ**, ៦៦ទំព័រ។

លោកបានបង្រៀនភាសាខ្មែរនៅវិទ្យាស្ថានភាសានិងអរិយធម៌បូព៌ាក្រុងប៉ារីសក្នុងឋានៈជាសាស្ត្រាចារ្យជំនួយសាស្ត្រាចារ្យ **អាឡាំងដានីញ៉ែល** (Alain DANIEL) ពីឆ្នាំ១៩៨៥រហូតដល់ចូល និវត្តន៍។

នាពេលដែលកម្ពុជាធ្លាក់ក្នុងកណ្ដាប់ដៃរដ្ឋអំណាចខ្មែរក្រហមលោកមិនអាចចូលទៅភ្នំពេញវិញបាន។លោកបានសិក្សាគណនេយ្យវិជ្ជាហើយបានធ្វើការក្នុងមុខវិជ្ជានេះនៅក្រុមហ៊ុនបារាំងមួយរហូតដល់ចូលនិវត្តន៍ តែលោកមិនចោលការស្រាវជ្រាវក្នុងភាសាវិទ្យាទេ។ លោកបានចងក្រងវាក្យស័ព្ទខ្មែរជាច្រើនម៉ឺនពាក្យក្នុងបំណងចង់ធ្វើជា **វចនានុក្រមខ្មែរជំនើបមួយ**។ នេះជាលទ្ធផលដែលលោកបានសិក្សាស្រាវជ្រាវប្រហែលកន្លះសតវត្សរ៍មក។ តែត្រូវវាយបញ្ចូលក្នុងម៉ាស៊ីនកុំព្យូទ័រ ហើយនឹងយកទៅបោះពុម្ពផ្សាយទៅថ្ងៃមុខប៉ុណ្ណោះ។ ភាសាខ្មែរយើងវិវត្តន៍ជា

និរន្តរ៍តាមតម្រូវការសង្គម, បច្ចេកវិជ្ជានិងវិជ្ជានានាឯទៀត។ ដូចនេះយើងយល់ហើយថាការសិក្សាស្រាវជ្រាវត្រូវការពេលវែង និងត្រូវមាន មធ្យោបាយសម្ភារៈ ព្រមទាំងថវិកា និងសុខភាពទៀត ។ល។

លោកបានរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញា **ប៉ុណ្ណារី** ជាសាស្ត្រាចារ្យនៅវិទ្យាល័យ ខ្មែរ-អង់គ្លេស (Lycée khméro-anglais) មានបុត្រា២នាក់គឺ **ជីវពល** និង **សិទ្ធីការ។** អ្នកគ្រូ **ប៉ុណ្ណារី** បានទទួលអនិច្ចកម្ម នាខែមេសា ២០០១នៅប្រទេសបារាំង។

លោកគ្រូ **ឡុចផ្ទេង** បានទទួលអនិច្ចកម្មនៅថ្ងៃ២០កុម្ភៈ ២០២០ ក្នុងជន្មាយុ៨៦ឆ្នាំដោយជរាពាធ ក្នុងមន្ទីរពេទ្យ ប្រទេសបារាំង។ សពលោកបូជានៅឈាបនដ្ឋាន «ពែរឡាឆែស»(Père La Chaise) ក្នុងក្រុងប៉ារីសនាថ្ងៃ២៧ខែកុម្ភៈ២០២០ ហើយបុណ្យទក្ខិណានុប្បទានប្រារព្ធនៅវត្ត«ពោធិវង្ស»នៅជាយក្រុងប៉ារីសនាថ្ងៃអាទិត្យទី១មិនា២០២០។

រូបថត គរុសិស្ស ជំនាន់ទី២ នៅវិទ្យាស្ថានជាតិគរុកោសល្យ ភ្នំពេញ
*១៩៥៩.១៩៦១។ នៅជួរទី១ សាស្ត្រាចារ្យ***កោដ៍វ៉ាន់សាក់** *អង្គុយទី១០ពីឆ្វេង*
ទៅស្តាំនៅជិតភរិយាលោកអ្នកស្រី **ស៊ុយស្ហាន** *ស្លៀកសំពត់ ផ្កា នៅជិត*
Claude Biessy*ស្លៀកខោអាវពណ៌ស ហើយនៅជិតលោកម្ខាងទៀតគឺ លោក*
សុងសេង *ជាអនុប្រធាន វិទ្យាស្ថាននេះ។ (រូបថត របស់សាស្ត្រាចារ្យ*
ឡុចផ្ទៃង៍, *១៩៥៩*).
*លោក***ឡុង៍សៀម***ឈរក្រោយបង្អស់ ទី៤ពីឆ្វេងទៅស្តាំ*
*លោក***ឡុចផ្ទៃង៍***ឈរក្រោយបង្អស់ ទី១២ពីឆ្វេងទៅស្តាំ។*

Cliché. Loch Phléng

នាមបុគ្គលិកសិក្សាទាំងនេះដឹងដោយលោកគ្រូម៉ក់គីននិងលោកគ្រូឡុចផ្លេង៖

-* 1er rang assis de gauche à droite : 1. Mme Ngèt Phun (frs), 2.Mme Ouy Po Ho (frs), 3. Mme ?, 4.M. Yos Man, 5. Vén. Thach Prang (prof. pali), 6. Prof. Khiev Komar, 7. M.?, 8. Prof. Claude Biessy, 9. Mme Prof. Suzanne Keng Vannsak, 10 . Prof. Keng Vannsak, 11. Prof. Son Sèn, 12. Mme Frse. Prof.?, 13. Prof. Boussineau, 14. Prof. Nhok Thèm, 15. Mme Chi Kim An.

-* 2ème rang debout de gauche à droite : 16.M. ?, 17. M. ?, 18.M.Touch To Sa, 19 M. Thach Chov, 20. M. Samreth Bo, 21. M. Kim Son Trinh, 22. M. Mok Mao, 23. M. Layr Kim Séng, 24. M.Leang Sun(hist-géo), 25. M.?, 26. M.?, 27.M.?, 28. M. Sakhân?, 29. M. Ing Thân, 29. M. Som Nau, 30. M. Ngau Va, 31. M. Chhit Sri, 32. M. ?, 33. M. Loek Rasi.

-* 3ème rang debout de gauche à droite : 34. M. ?, 35. M. ?, 36. M. ?, 37. M. Ul Chan, 38. You Sam Bo, 39. M. Chuon Vang, 40. M. Saing Rin, 41. M. ?, 42. M. ?, 43. M. Pèn Pé Né, 44. M. ?, 45. M.?, 46. M. ?, 47. M. Chhay Boun Chorn, 48. M. Toeng Chhan, 49. M. Chea Chhean, 50. M. ?, 51. M.?, 52. M. Nhep Mao.

-*4ème rang debout de gauche à droite: 53. M. Kov Sun, 54. M. ?, 55. M. Ly Yam, **56. Long Seam**, 57. M. ?, 58. M. Kov Toek Hieng, 59. M. Chhiev Chrien, 60. M. ?, 61. M. Ros Pin, 62. M.?, 63. M. Lon Kéng, 64. M. **Loch Phléng**, 65. M. Suon Soun Maly, 66. Ouk Samân, 67. M. Var Sim Samreth, 68. M. ?, 69. M. ?, 70. Yim Santhor (physique-chimie), 71. M. Som Hol, 72. M. Chim Sunly.

ស្នាដៃជាសៀវភៅនិងអត្ថបទសិក្សា៖

ឡុច ផ្លេង

ប្រជុំវប្បធម៌

95 rue de Sèvres
75006 Paris

គ.ក.ប.បកប្រែ

វិទ្យាស្ថានជាតិខេមរយានកម្ម

ភ្នំពេញ ១៩៧៣


ក្រសួងអប់រំជាតិ
សទ្ទានុក្រម
ខេមរយានកម្ម
បារាំង - ខ្មែរ
ខេមរយានកម្ម



គណៈកម្មការអនុម័តពាក្យ

តែងតាំងដោយលិខិតបង្គាប់ការលេខ ៦៦៨ អស១–៧១ ចុះថ្ងៃទី ១៣ ខែធ្នូ ១៩៧១ និងលេខ ១៦៦ កបុ. ចុះថ្ងៃទី ០៩ ខែកុម្ភៈ ១៩៧៣ ។

សមាសភាពគណៈកម្មការ

១. លោក	ឡុច ផ្លែង	ប្រធាន	
២. —	ឃួន ឃិន	អនុប្រធានទី ១	
៣. អ្នកស្រី	លី គឹមអួង	អនុប្រធានទី ២	
៤. —	សោ ថៃសេង	សមាជិក	
៥. លោក	កែន ឃុន	—	
៦. —	វ៉ៃ ពៅ	តំណាងគ.ក.ប.	វេយ្យាករណ៍
៧. —	ឈន លី	—	គណិតវិទ្យា
៨. —	ស៊ិន ងួនហេង	—	រូបវិទ្យា - គីមី
៩. អ្នកស្រី	ថាច់ អ៊ឹង	—	ធម្មជាតិវិទ្យា
១០. លោក	ស្រី ស្រុន	—	ប្រវត្តិវិទ្យា
១១. —	មៀវ ណាំ	—	ភូមិវិទ្យា
១២. —	ស៊ូ សយ	—	កីឡា
១៣. —	ឈុន ខុន	—	កសិកម្ម
១៤. —	គី នាង	—	អក្សរសាស្ត្រ
១៥. —	ព្រំ ខាត់	—	រោងជាង
១៦. អ្នកស្រី	លី ជានី	—	ទស្សនវិជ្ជា
១៧. —	តាន់ បេងភួន	—	វិជ្ជាមេផ្ទះ

លោកគ្រូ ឡុច ផ្លែង ជា ប្រធានគណៈកម្មការ អនុម័តពាក្យ



កំរងពត៌មាន នៃអក្សរសាស្ត្រនិងមនុស្សសាស្ត្រ ភ្នំពេញ
ឆ្នាំសិក្សា ១៩៧០-៧១។

- 35 -

B- Méthodes et Procédés de la Littérature :
- Méthodes simples
- Méthodes scientifiques
- Méthodes philosophiques

C- Théories littéraires :
- Le Réel
- Le Merveilleux
- La Synthèse du Réel et du Merveilleux

2º Programme de Littérature khmère
par M. LOCH PHLENG (2h hebdomadaires)

ក - អក្សរសិល្ប៍ទូទៅ :

- ន័យអក្សរសិល្ប៍
- វត្ថុអក្សរសិល្ប៍
- មុខងារអក្សរសិល្ប៍
- បំណងអក្សរសិល្ប៍
- លក្ខណៈអក្សរសិល្ប៍
- ប្រវត្តិអក្សរសិល្ប៍
- សភាពអក្សរសិល្ប៍
- អត្ថបទអក្សរសិល្ប៍
- ប្រភេទអក្សរសិល្ប៍
- អ្នកអក្សរសិល្ប៍
- ចលនាអក្សរសិល្ប៍
- បញ្ហាអក្សរសិល្ប៍
- ទ្រឹស្តីអក្សរសិល្ប៍
- វិធីអក្សរសិល្ប៍
- រសអក្សរសិល្ប៍

ខ - អក្សរសិល្ប៍ពិសេស :

១ - រឿងព្រេង
២ - រឿងល្បើក
៣ - រឿងជាតក
៤ - រឿងប្រលោមលោក
៥ - រឿងល្ខោន :
- ន័យ
- ចំណងជើង
- ចំនួន
- អ្នកនិពន្ធ
- កាលកំណត់
- ប្រភព
- សភាព
- ប្រភេទ
- ចលនា
- តួ
- ទីកន្លែង
- ពេលវេលា
- បញ្ហា
- អត្ថរូប
- អត្ថរស
- តម្លៃ

3º ការសិក្សាអក្សរសិល្ប៍ខ្មែរផ្នែកពុទ្ធនិយមដោយលោក អ៊ឹង គឹម អេង (២ ម៉ោងក្នុង ១ សប្តាហ៍

ក - ផ្នែកទ្រឹស្តី :

- និយមន័យទូទៅនៃពាក្យអក្សរសិល្ប៍ខ្មែរ
- និយមន័យនៃពាក្យអក្សរសិល្ប៍ខ្មែរផ្នែកពុទ្ធនិយម
- ពុទ្ធប្រវត្តិសង្ខេប
- ពុទ្ធសាសនា និងពុទ្ធនិយម
- អក្សរសិល្ប៍ពុទ្ធនិយម និងអក្សរសិល្ប៍ខ្មែរពុទ្ធនិយម
- ពោធិសត្វក្នុងថេរវាទ និងពោធិសត្វក្នុងមហាយាន
- លក្ខណៈពិសេសនៃពោធិសត្វ និងលក្ខណៈអាទិទេព
- ទសបារមី និងទសពល និងទសពិធរាជធម៌
- ពុទ្ធលទ្ធិដោយសង្ខេបអំពីកម្មផល អំពីអនត្តៈ អំពីអរិយសច្ចៈ

កម្មវិធីសិក្សាអក្សរសិល្ប៍ ខ្មែរ ដោយ លោកគ្រូឡុចផ្លេង នៅមហាវិទ្យាល័យ
អក្សរសាស្ត្រនិងមនុស្សសាស្ត្រ
ឆ្នាំសិក្សា ១៩៧០-៧១។


Rapport de fin d'année du 3e Cycle

1973 _ 74

LE SYSTEME PHONOLOGIQUE DU KHMER

par

LOCH PHLENG

Sous la direction de Monsieur René GSELL,

Professeur à l'Institut d'Etudes Linguistiques et Phonétiques de l'Université de la Sorbonne Nouvelle (Paris III)

របាយការណ៍ បញ្ចប់ឆ្នាំ១៩៧៣ - ៧៤ ថ្នាក់បណ្ឌិតតតិយភូមិ លោកគ្រូឡុច ផ្លេងនៅវិទ្យាស្ថានសិក្សាភាសាវិទ្យា និង ស័ទ្ទវិទ្យា នៃសាកល វិទ្យាស្ហោបោនទី ៣, ប្រធានបទស្តីពី **ប្រព័ន្ធមូល ស័ទ្ធវិទ្យាខ្មែរ**, ៦៦ទំព័រ។



ទស្សនាវដ្ដី សាស្ត្រាចារ្យ, ឆ្នាំទី៥, ១៩៦២។

មាតិការឿង

កថាមុខ

បិត្ត - គរុកោសល្យ .... ទំព័រ

Pour une refonte totale de notre enseignement 1
L'enseignement Secondaire National et 5
Les possibilités de notre langue nationle 9
សំលៀកបំពាក់ នៃ សិស្សយើង 13

កិច្ចការសមាគម 18

ស.ស.ខ. ថ្វាយពរសម្តេចឪ 20
ញត្តិទី ១ 22
ញត្តិទី ២ 25
ញត្តិទី ៣ 27
ស ស.ខ. ឆ្លើយតបនឹងពួក "ខ្មែរសេរី" 30
ស្ថានភាពខាងហិរញ្ញវត្ថុ 35

កំណាព្យ 37

ការស្រាវជ្រាវ

ប្រភពរឿងកាកី 39
រុក្ខជាតិបង្កើតកូនចៅ 46
អំពីសត្វខ្មែរ 49

អត្ថបទនឹងឯកសារ

កោះសន្តិភាព 53
សេចក្តីចំរើន នៃ វិទ្យាសាស្រ្ត 55
អង្គការសហប្រជាជាតិ 56
លទ្ធផលបណ្តោះអាសន្ន នៃ ការជំរឿន 57
La journée d'une petite japonaise 59
Information universitaire 63
Liste nominative des étudiants 66
Afrique 1963 69
Informations scientifiques 71

ប្រភពរឿងកាកី

ឡុច - ឆៀង
សាស្ត្រាចារ្យ វិទ្យាល័យព្រះស៊ីសុវត្ថិ

ខ្ញុំបានអានសេចក្តីអធិប្បាយអំពីប្រភពរឿង ‘‘ កាកី ’’ ក្នុងសៀវភៅ ‘‘ អក្សរសិល្ប ប្រវត្តិសៀម ’’ របស់លោក ‘‘ ប៉ឿង ’’ សាស្ត្រាចារ្យពិសេស ទទួលភារៈបង្រៀនភាសាសៀម និង អក្សរសិល្បវិជ្ជាសៀម នៅសកលវិទ្យាល័យ <<ចូឡាលង្ករណ៍>> និពន្ធក្នុង ព. ស. ២៤៩៥ តាំងពីដើមឆ្នាំ ១៩៦០ម៉្លេះ ។

ហេតុដែលខ្ញុំមិនបង់ចុះផ្សាយ ពីព្រោះខ្ញុំដំអក់ចាំទទួលការពិសោធន៍ខាងការបង្រៀនរឿងកាកីខ្មែរ ឲ្យបានយូរបន្តិចសិន ។ ឥឡូវនេះដល់ឆ្នាំទី ៣ នៃការបង្រៀនរឿងនេះហើយ ។ ដោយបានសិក្សាប្រៀបធៀបនូវអត្ថបទរឿងក្នុងភាសាទាំងពីរទៅ ខ្ញុំឃើញថារឿងមានសំរស់លំអម្យ៉ាងម្នាក់ ។

ខ្ញុំសូមលើកយកចំណុចមួយមកប្រដូចគ្នាមើល ចំណុះនោះគឺវត្ថុបំណងរបស់កវីក្នុងការនិពន្ធរឿង ។ កវីសៀមមានបំណងចង់ទុករឿងកាកីនេះជាដំបូន្មានសំរាប់ទូន្មាន ‘‘ គាស្ត្រី ’’ ក្នុងព្រះរាជវង្សានុវង្ស ចំណែកឯព្រះរាជកវីខ្មែរ ព្រះអង្គចង់ទូន្មាន ‘‘ ស្ត្រី ’’ ទាំងឡាយមិនចំពោះ ។ ដូច្នេះ យើងឃើញថា ទស្សនៈរបស់ព្រះរាជកវីខ្មែរ ដូចជាទូលំទូលាយជាង ។

យើងដឹងស្រាប់ហើយថា "រឿងកាកី" ជាស្នាដៃមួយដ៏ឆ្នើមក្នុងអក្សរសិល្ប៍ខ្មែរ ព្រះរាជនិពន្ធឡើងដោយព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គ "ឌួង" ព្រះបរមកោដ្ឋ ។

ព្រះបាទសម្តេចព្រះអង្គ "ឌួង" ជារាជបុត្រសអង្គទី ៤ នៃព្រះបាទសម្តេចព្រះអង្គ "អេង" ។ ព្រះអង្គទ្រង់ប្រសូត នៅ ព. ស. ២៣៣៩ គ. ស. ១៧៩៦ ។ ព្រះអង្គឡើងសោយរាជ្យនៅ គ. ស. ១៨៤១ ហើយទ្រង់ទទួលប្រាប្តាភិសេកនៅក្រុងឧដុង្គ ក្នុង ព. ស ២៣៩០ គ. ស. ១៨៤៣ ។ ទ្រង់សោយទិវង្គតនៅថ្ងៃសុក្រ ៥ កើត ខែកត្តិក ឆ្នាំវកតោស័ក ព. ស ២៤០៣ ត្រូវនឹងថ្ងៃទី ១៩ ខែតុលា គ. ស. ១៨៦០ ក្នុងព្រះជន្មាយុ ៦៤ ព្រះវស្សា ។

ព្រះរាជជីវប្រវត្តិ និងកិច្ចការស្នាព្រះហស្តរបស់ព្រះអង្គ មានអធិប្បាយដោយពិស្តារក្នុងពង្សាវតារ នៃប្រទេសកម្ពុជាស្រាប់ទៅហើយ យើងមិនចាំបាច់លើកយកមករៀបរាប់ក្នុងទីនេះទៀតទេ ។

ព. ស. ២៣៥៨ គ. ស. ១៨១៥ ជាសករាជ ដែល "រឿងកាកី" នេះ ត្រូវបាននិពន្ធឡើង ក្នុងយុវវ័យរបស់ព្រះអង្គ (១៩ ព្រះវស្សា) មុនឡើងគ្រងរាជ្យ ។

ឥឡូវនេះ យើងនឹងភ្ជាប់ "រឿងកាកី" នេះទៅនឹងការស្រាវជ្រាវរកប្រភពដើមនៃរឿង ។

ប្រភពដើមនៃរឿង

ព្រះបាទអង្គ "ឌួង" ទ្រង់បានបញ្ចប់ "រឿងកាកី" ដោយប្រយោគនេះ ៖

"ដំណើរនាងកាកី ប្រែសេចក្តីសៀមភាសា

ជាពាក្យខ្មែរកាព្យា សូរេចរឿងចប់ម៉្លេះហោង" ។

ពិតមែនតែមានសេចក្តីថា ព្រះអង្គបានប្រែរឿងនេះចេញពីភាសាសៀមក៏ដោយ ក៏ព្រះអង្គបានកែឡៃតុបតែងពាក្យពេចន៍ ដំណើររឿង ឲ្យស្រប‌ទៅតាមចិត្ត គំនិត វប្បធម៌

សង្គមធម៌របស់ខ្មែរសុទ្ធសាធ ហើយក៏សៀមនេះទៀតក៏ពុំមែននិពន្ធរឿងនេះឡើងដោយចិត្តគំនិតផ្ទាល់ខ្លួននោះឡើយ ។ គេបានផ្តិតចម្លង "រឿងកាកី" នេះចេញមកពីរឿងក្នុងនិបាតជាតកពីររឿង គឺ ៖

ក - រឿង "កាកាតិជាតក" ៖ ក្នុងជាតកនេះ នាង "កាកី" មានឈ្មោះហៅថា "កាកាតិ" ចំណែកឯគន្ធព្វ គេឲ្យឈ្មោះថា "នាដកុវេរ" ។ "កាកាតិជាតក" នេះមានដំណើររឿងខ្លី ចប់ត្រង់ស្តេចគ្រុឌនាំនាង "កាកាតិ" មកប្រគល់ថ្វាយព្រះបាទព្រហ្មទត្តវិញប៉ុណ្ណោះ ។

ខ - រឿង "កុណាលជាតក" ជាជាតកមួយទៀត ដែលមានដំណើររឿងដូចគ្នា នឹង "កាកាតិជាតក" ខុសគ្នាតែត្រង់កន្លែងដែលនាងកាកីនោះ មានឈ្មោះថា "កាកវន្តិ" វិញ ។

រឿងជាតកទាំងពីរខាងលើនេះ កំពុងស្ថិតនៅក្នុងការស្រាវជ្រាវរកឯកសារជាភាសាខ្មែរតទៅទៀត ។

អាស្រ័យហេតុនេះ គប្បីយើងធ្វើសេចក្តីសន្និដ្ឋានថា ច្បាប់ដើមនៃរឿងជាភាសាបាលី បន្ទាប់ចៅពញាព្រះឃ្លាំង "ហុន" បានរៀបរៀងមកជាភាសាសៀម ហើយចុងក្រោយបង្អស់ ជាភាសាខ្មែរដោយព្រះបាទអង្គ "ឌួង" ។ តាមសេចក្តីនេះ ព្រះបាទអង្គ "ឌួង" បានបញ្ជាក់ភស្តុតាងក្នុងព្រះរាជាម្ភកថា ជាពាក្យពេចន៍ពីរប្រយោគដាច់ពីគ្នាថា ៖

..."បរាគបុរី បុរាណវណី ៗ ស្ថិតនៅនា ស្រុកទេពនគរ កុលករចិន្តា តែងតាមបទធា ឲ្យលោកសំដែង ។"...

..."ពាក្យពោលពុំពី ពេះពេបនៃនិ- ធានតាមបទធា ឲ្យលោកដើមអាទិ ដ្បិតជាតិប្រាជ្ញា ចេះចង់សាសនា ពុំសូវគួរសម ។"...

តាមសម្មតិកម្ម ព្រះបាទអង្គឌួង "ប្រាកដ" ជាបានទត បានអានអត្ថបទដើមជាភាសាបាលីពុំខាន ។

តទៅទៀតនេះ យើងនឹងលើកយកសេចក្ដីផ្ដើមក្នុងភាសាទាំងពីរ ដែលជាលក្ខណៈគោលសំខាន់បណ្ដាលឲ្យកវីនិពន្ធ " រឿង " កាកី នេះឡើង មកប្រៀបប្រដូចគ្នាមើល ។ បើយើងប្រែតាមពាក្យពេចន៍មួយម៉ាត់ៗ ដោយមិនគិតដល់វិធីចាប់ចុងចួនក្នុងកំណាព្យ ពាក្យប្រារព្ធជាភាសាសៀមនោះ នឹងបានសេចក្ដីដូចតទៅនេះ៖

" សូមសំដែងថែងនិទានក្នុងកាលមុន កាលគ្រាអង្គទ្រង់សិលជិនវរ ត្រាប់សព្វរប៉ន ប្រយោជន៍ពោធិញ្ញាណ ស្វាយព្រះជាតិជាសកុណាពញាសត្វ បានដករឿងជាតកមកបរិហារ ប្រយោជន៍សំដែងថែងពិតចិត្តស្រីពាល ឲ្យប្រុសជាញដឹងដើងក្សត្រី " ។

បន្ទាប់មក សូមអានសេចក្ដីជាខ្មែរក្នុងព្រះរាជារម្ភកថា វិញ៖

" ដំណើរដំណាល ស្រីស្រស់ពុតពាល ចិត្តដូសាមាន្យ ធុតាឲ្យស្ត្រី លោកីមិញមាន ចិត្តប្រងប្រាសប្រាណ ប្រាសប្រែអនិច្ចា " ។

ក្នុងរឿងកាកីសៀមជាពាក្យកាព្យ យើងគប្បីសង្កេតពិចារណា តាមវគ្គទាំង ៣ ដូចតទៅនេះ៖

ក) វគ្គទី ១ – ចាប់តាំងពីដើមរឿងរហូតទៅដល់កន្ទេលដែលស្ដេចគ្រុឌ វិលត្រឡប់មកលេងបាស្កាជាមួយនឹងស្ដេចព្រហ្មទត្តម្ដងទៀត ក្រោយដែលបានលួចនាងកាកីទៅហើយ ។

បំពោះវគ្គនេះ មានអ្នកខ្លះឲ្យយោបល់ថាពុំមែនជាសំនួនវោហារ របស់ចៅពញាព្រះឃ្លាំង " ហុន " ឡើយ គឺប៉ុន្តែប្រហែលជារបស់ព្រះមហាយសរា អ្នកនិពន្ធរឿង " ពាលីប្រដៅប្អូន " ទៅវិញ ។

ខ) វគ្គទី ២ តែងជាបទមហោរី ចាប់តាំងពីគន្ធ័នដេញពិណផ្កាញ់ផ្កាលស្ដេចគ្រុឌ រហូតទាល់តែដល់កន្ទេលនាងកាកីត្រូវបណ្ដែតពោងពាយ ។ វគ្គនេះប្រាកដជាស្នាដៃរបស់ចៅពញាព្រះឃ្លាំង " ហុន " មែន ។

គ) វគ្គទី ៣ – វគ្គនេះបរិយាយតទៅទៀត អំពីនាងកាកីរសាត់តាមពោធិ៍ពាយ ទៅជួបនឹងនាយសំពៅកណ្ដាលសមុទ្រ ខូចខ្លួនខូចប្រាណជាមួយនឹងនាយសំពៅ រហូតពីនាយសំពៅធ្លាក់ទៅដៃចោរ ហើយនៅទីបំផុតបានទៅជាមហេសីរបស់ព្រះបាទទសវង្ស ស្ដេចដែលសោយរាជ្យនៅនគរអភ័យសាលី ។ និយាយពីរឿងរ៉ាវទៅនៅនគរពារាណសីវិញ ដល់ព្រះបាទព្រហ្មទត្តទ្រង់សោយទិវង្គតទៅ ពួកសេនាមាត្យសព្វមុខមន្ត្រីតូចធំក៏មូលមតិគ្នាលើកនាងគុវេរគន្ធព្វជាស្ដេចសោយរាជ្យស្នង ។ កាលបើដឹងថានាងកាកីនៅមានជីវិតរស់នៅឡើយនៅនគរអភ័យសាលី គន្ធព្វក៏លើកទ័ពទៅវាយដណ្ដើមយកនាងមកវិញបាន ហើយអភិសេកនាងកាកីឡើងជាអគ្គមហេសី ។

កវីដែលនិពន្ធវគ្គទី ៣ បន្ថែមជាថ្មីនេះ មានឈ្មោះហៅថា "ជោតិ" ងាមត្រកូល "មណីរត្ន" ។ ពាក្យពេចន៍សំនួរវោហារក្នុងវគ្គបន្ថែមនេះ មានសុភាពទន់ភ្លន់ជាងវគ្គទី ១ និងវគ្គទី ២ ឆ្ងាយណាស់ ។ បានជានិពន្ធថែមថ្មី ក៏ព្រោះតែកវីនេះយល់ថា រឿងកាកីនេះហាក់ដូចជាមិនទាន់ចប់សព្វគ្រប់ គេចង់ធ្វើឲ្យនាងកាកីគប់ប្រសព្វនឹងឧបសគ្គនានាសិន រួចហើយបានមកសោយសុខតាមធម្មតាវិញ ។

ខ្ញុំសូមជូនជីវប្រវត្តិរបស់ចៅពញាព្រះឃ្លាំង "ហុន" ទុណាជាពុំមែនជាកវីខ្មែរក៏ដោយ តែជីវប្រវត្តិនេះអាចនឹងមានអត្ថប្រយោជន៍ទាក់ទងនឹងការសិក្សាអក្សរសិល្ប៍ខ្មែរយើងខ្លះជាពុំខាន ។

ជីវប្រវត្តិរបស់កវី.–

ចៅពញាព្រះឃ្លាំង "ហុន" ជាបុរសសំខាន់មួយនាក់ក្នុងសម័យក្រុងរតនកោសិន្ទ្រ (ក្រុងទេពព្រះនគរបាងកកសព្វថ្ងៃនេះ) ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះពុទ្ធយ៉តហ្វាចូឡាលោក (ប្រសូត ព.ស. ២ ២៧៩ គ្រងរាជ្យ ព.ស. ២.៣២៥, សោយទិវង្គត ព.ស. ២ ៣៥២) ។ ចៅពញាជាអ្នកចំបាំងផង ជាសេនាមាត្យជាន់ខ្ពស់ផង

ព្រមទាំងជាកវីឯកក្នុងព្រះរាជមន្ទីរផង ។ យើងដឹងដោយស្ដួចស្ដើងណាស់អំពីជីវប្រវត្តិរបស់កវីនេះ ។ សៀវភៅលំដាប់នាមត្រកូល " ប៊ុងឡុង " បានបញ្ជាក់ថា លោកជាបុត្ររបស់ចៅពញាបតិន្ទ្រសុរិន្ទ្រពុទ្ធជ័យ " ប៊ុន - មី " និងលោកស្រី " ចំរើន " ។

ដំបូងលោកមានយសសក្ដិជាហ្លួង សរវិជិត នាយដានស្រុកទទ័យ ។ ក្នុងពេលចលាចលនៅក្រុងធនបុរី ហ្លួងវិជិត នាយប៊ុនណាក បានម៉ៃឡា និងពញាសគ៌ បាននាំគ្នាលើកបក្សពួកចូលមកឡោមព័ទ្ធព្រះរាជវាំង ។ កាលបើសម្ដេចព្រះចៅក្រុងធនបុរី (តាក - ស៊ិន) ទ្រង់ចុះចាញ់និងលះបង់រាជ្យចេញសាងព្រះផ្នួសនៅវត្តអរុណរាជវរារាម ហើយ ហ្លួងវិជិតនិងបក្សពួកក៏បាននៅថែរក្សានគរ ។ ក៏ប៉ុន្តែ ដល់ក្រោយមក ពួកអ្នកចូលមកក្ដាប់អំណាចថ្មីនេះ មានយោបល់ទាស់ទែងខ្វែងគំនិតវិវាទប្រឆាំងគ្នាឯងឡើង ។ ខណៈនោះ សម្រេចព្រះពុទ្ធយ៉តហ្វាចូឡាលោក (កាលនៅជាសម្ដេចពញាមហាក្សត្រិយ៍សឹកនៅឡើយ) កំពុងលើកទ័ពមកវាយប្រទេសខ្មែរ ។ ដល់ព្រះអង្គទ្រង់ជ្រាបហេតុការណ៍ចលាចលនៅក្រុងធនបុរីបែបនេះភ្លាម ទ្រង់ក៏ប្រញាប់ប្រញាល់លើកទ័ពត្រឡប់មកវិញ កាត់តាមស្រុកប្រាចីនបុរី (បសុមបុរី) ។ ហ្លួងសរវិជិតបានចេញទៅទទួលព្រះអង្គនៅវាល " សែងសែប " ក្រាបថ្វាយទូវពត៌មានសំខាន់ៗ ទាំងអស់ហើយបានក្រាបទូលអញ្ជើញព្រះអង្គនាំទ័ពចូលព្រះនគរ ។

ដល់សម្ដេចព្រះពុទ្ធយ៉តហ្វាឡើងសោយរាជ្យ ព្រះអង្គក៏បានតែងតាំងហ្លួងសរវិជិតជា " ពញាពិពឌ្ឍនកោសា " តមកក៏បានដំឡើងតំណែងជា " ពញាព្រះឃ្លាំង " ។ លោកបានបំពេញកិច្ចរាជការរហូតទាល់តែទទួលអនិច្ចកម្មនៅ ព.ស ២.៣៤៨ គ.ស. ១.៨០៥ ។

លោកបានទុកស្នាដៃអក្សរសិល្បដូចតទៅ ៖

- លិលិតស្រីវិជ័យ ជាតក

- លិលិតពេជ្រមកុដ

- លិលិតព្យុហយាត្រាពេជ្រក្លួន

- ឥនាវ

- មហាជាតកបទពាក្យ៧ បំពោះតែកុមារកណ្ឌ និង មទ្រីកណ្ឌ

- បទមហោរី រឿងកាកី

លោកបានអនុគ្រោះប្រែរឿងសាមកុក និងបានចិត្តនូវរឿងរាជាធិរាជ ដោយកិច្ច សហប្រតិបត្តិការ ជាមួយពញាឥន្ទ្រអគ្គរាជ, ព្រះកិរម្យរស្មី និង ព្រះស្រីគូរប្រិជា ។

សេចក្តីសង្ខេប .-

១- សម្តេចព្រះពុទ្ធឃោសាចារ្យ បានរៀបអភិសេកព្រះអង្គ " អេង " ដែល ជាព្រះរាជបិតារបស់ព្រះបាទអង្គ " ឌួង " ឲ្យឡើងសោយរាជ្យជាសម្តេចព្រះនារាយណ៍ រាមាធិបតី អម្ចាស់ផែនដីក្រុងកម្ពុជាធិបតី (គ. ស ១៧៧៩ - ១៧៩៦) ។

២- លិលិត ៖ សៀមសំដៅដល់អត្ថបទដែលគេនិពន្ធឡើងដោយផ្សំកំណាព្យ និង ពាក្យរាយឲ្យតរណ្តំគ្នា ។

៣ - បទពាក្យ៧ ៖ សៀមសំដៅដល់បទដែលប្រើក្នុងរឿងមហាជាតក ហើយ ខ្មែរយើងហៅថា " បទកាកគតិ " ទៅវិញ ។ ចំពោះបទកាព្យនេះ សៀមសំដៅ ដល់ពាក្យពេចន៍ឃ្លាប្រយោគសរសេរតាមធម្មតាគ្មានការរណ្តំចាប់ចុងចួនគ្នាឡើយ ។

" ស្នាចហង្សតែងស្រង់ស្រះស្រី ហង្សអ្វីអប្រិយ មកដឹកឯទឹកថ្លុកល្អក់ ។
រូបល្អចិត្តក៏អាក្រក់ ស្អុយព្រៃលាមក ក្រអូបតែក្លិនអសារ ,, ។ (កំហែងស្តេចគ្រុឌ)

INVITATION

Monsieur LOCH Phleng
Monsieur LOCH Thirahpol & Madame LOCH Sokoma et famille
Monsieur LOCH Sitthikar
Monsieur LOCH Chhanchhai
Monsieur LOCH Chirak & Madame LOCH Bounnuang et famille
ont la douleur de vous faire part de la perte de

Madame LOCH Ponnary

(Ancienne Enseignante au Lycée Khméro-anglais à Phnom Penh)

son épouse, leur mère et leur belle-soeur, survenue le jeudi 29 mars 2001

Les cérémonies en sa mémoire se dérouleront :

Incinération :
Mercredi 4 avril 2001 à 16 heures 15
au Crématorium du Père Lachaise, rue Rondereaux, 75020 PARIS,
tél : 01.46.36.28.24

Rite religieux :
Jeudi 5 avril 2001 à 9 heures 30
à la Pagode Bodhivansa, 101, boulevard de la République, 77420 CHAMPS SUR MARNE,
tél : 01.60.06.44.98

LOCH Phleng
10, Allée Mansart
77185 LOGNES
Tél. : 01 60 17 30 17

LOCH Thirahpol
114, Rue du Parc
91180 Saint Germain Lès Arpajon
Tél. 01 60 85 19 81 – 06 68 90 42 72

សំបុត្រអញ្ជើញញាតិមិត្តចូលរួមបុណ្យសព ភរិយា លោកគ្រូ ឡុចផ្លេង នាមដើមអ្នកគ្រូ ឡុចប៉ុណ្ណារី ៤មេសា២០០១។

បុណ្យនៅវត្ត ពោធិវង្ស ជាយក្រុងប៉ារីស។ ពីឆ្វេងទៅស្តាំ៖ លោកគ្រូ ឃីងហុកឌី លោកគ្រូ អ៊ុំចសុធន, លោកគ្រូ ឃីផាន្ដា, លោកគ្រូឡុចផ្ទៃង, លោកគ្រូ ម៉ក់ភឹន, លោកគ្រូ រស់វ៉ាន់ថា, លោកគ្រូ ថោងផាន (រូបថតឆ្នាំ២០១១)។

លោកគ្រូឡុចផ្ទៃង និងលោកគ្រូ ម៉ក់ភឹន ចូលរួមពិធីបុណ្យ១០០ថ្ងៃក្រោយពេលអនិច្ចកម្មករិយាលោកគ្រូ ថោងផាននៅវត្តពោធិវង្ស ជាយក្រុងប៉ារីស៍ (រូបថតឆ្នាំ២០១៦)។

លោកគ្រូ ឃីងហុកឌី, លោកគ្រូម៉ក់ភឺន, អ្នកស្រី ម៉ក់តាំងអ៊ីម, អ្នកគ្រូឡុចប៉ុណ្ណារី
លោកគ្រូ ឡុចផ្ទៃង, កុមារីម៉ក់ (រូបថតឆ្នាំ១៩៧៦ នៅក្រុងប៉ារីស)។